

# ការជម្រះក្ដីដោយគ្មានជនជាប់ចោទ: សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅ កម្ពុជា

របាយការណ៍សង្ខេប លីកាដូ
ខែកុម្ភៈ ឆ្នាំ២០១០


លីកាដូ
សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights
LICADHO

# ការជម្រះក្តីដោយគ្មានជនជាប់ចោទ: សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជន នៅកម្ពុជា

របាយការណ៍សង្ខេប អង្គការ លីកាដូ

ខែកុម្ភៈ ឆ្នាំ២០១០

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ លីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ ហើយស្ថិតនៅជួរមុខគេក្នុងកិច្ចខិតខំប្រឹងប្រែងការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមកិច្ច នៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិទាំងនោះពីរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល លីកាដូបានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងជាអ្នកឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខា១២ខេត្តផ្សេងទៀត។

**អង្គការ លីកាដូ បន្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំ២ពីរ :**

**កម្មវិធីឃ្លាំមើល និងកិច្ចការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលបម្រើការងារក្នុងជួររាជរដ្ឋាភិបាល ការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការប្រមូល និងស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលបម្រើការងារក្នុងជួររាជរដ្ឋាភិបាល និងអំពើហិង្សានានាលើស្ត្រី និងកុមារ។ ជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់នូវការប្រឹក្សាផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ពួកគាត់ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវកិច្ចការពារផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន១២ពន្ធនាគារ ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស និងគ្រួសារដែលនៅក្នុងតំបន់តាំងទីលំនៅថ្មី។
- **សេវាកម្មសង្គមកិច្ច:** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយជាសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីផ្សព្វផ្សាយ និងតស៊ូមតិ**

- **ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន :** អ្នកតស៊ូមតិផ្តល់ការអប់រំដល់ក្រុមគោលដៅជាក់លាក់ គាំទ្រការបង្កើតបណ្តាញការពារនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឱ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់តាមរយៈស្ត្រី យុវជន និងកុមារ។

- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយ លីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីធានាថា ព័ត៌មានត្រឹមត្រូវ ងាយស្រួលក្នុងការស្វែងរកវិភាគ ផលិតជារបាយការណ៍សម្រាប់សាធារណជនទូទៅ (ជាសៀវភៅរបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

## ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:


លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ១៦ ផ្លូវលេខ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១
ទូរសារ: (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦
អ៊ីម៉ែល: contact@licadho-cambodia.org
គេហទំព័រ: http://www.licadho-cambodia.org

# មាតិការ


សេចក្តីផ្តើម ... ១

ពិរុទ្ធជនដែលជាប់បណ្តឹងឧទ្ធរណ៍ ... ១

និដ្ឋភាពច្បាប់ជាតិ និងច្បាប់អន្តរជាតិ ... ៣

ការដឹកជញ្ជូនអ្នកទោសនៅកម្ពុជា ... ៤

ធាតុពិតៈ សវនាការតុលាការសាលាឧទ្ធរណ៍ដោយគ្មានជនជាប់ចោទ ... ៦

អនុសាសន៍ ... ៨

## សេចក្តីផ្តើម

នៅកម្ពុជាបច្ចុប្បន្ន មានពិរុទ្ធជនជាង ៥០០ នាក់ ដែលប្តឹងឧទ្ធរណ៍កំពុងជាប់ឃុំឃាំងក្នុងពន្ធនាគារ តាមបណ្តាខេត្តនានា ដែលខេត្តខ្លះមានចម្ងាយរាប់រយគីឡូម៉ែត្រ ពីតុលាការសាលាឧទ្ធរណ៍ដែលមានតែមួយគត់នៅរាជធានីភ្នំពេញ។ ដោយសារកម្ពុជា ជាប្រទេសមួយដែលស្ទើរតែគ្មានមធ្យោបាយដឹកជញ្ជូនពិរុទ្ធជន ពីខេត្តនានា ដែលនៅឆ្ងាយរាប់រយគីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ដូច្នេះ ពិរុទ្ធជនដែលជាប់បណ្តឹងឧទ្ធរណ៍ទាំងនេះ កំពុងប្រឈមការលំបាកយ៉ាងខ្លាំង ក្នុងការទទួលបាននូវការវិនិច្ឆ័យទោស ដោយចំពោះមុខនៅតុលាការសាលាឧទ្ធរណ៍ ដែលនេះគឺជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់មួយនៃសវនាការដែលប្រកបទៅដោយភាពស្មើភាព និងយុត្តិធម៌នៅចំពោះមុខច្បាប់។ គ្រោះថ្នាក់ដ៏ធំមួយនេះបាននឹងកំពុងត្រូវគេមើលរំលង (សិទ្ធិក្នុងការទទួលបាននូវការពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់ ដើម្បីអោយប្រាកដថា ការវិនិច្ឆ័យ និងផ្តន្ទាទោសត្រូវប្រព្រឹត្តទៅដោយត្រឹមត្រូវតាមច្បាប់)[១]។

## I. ពិរុទ្ធជនដែលជាប់បណ្តឹងឧទ្ធរណ៍

រហូតមកដល់ខែមករា ឆ្នាំ២០១០ នេះ អគ្គនាយកដ្ឋានពន្ធនាគារកំពុងឃុំឃាំងទណ្ឌិតសរុបចំនួន ៨.២៣៥ នាក់ នៅក្នុងពន្ធនាគារចំនួន ១៨ កន្លែង ដែលអង្គការលីកាដូ តែងតែឃ្លាំមើលជាប្រចាំ។ ក្នុងចំណោមទណ្ឌិតខាងលើនេះ ៥.២៥៣ នាក់ កំពុងឃុំឃាំងនៅក្នុងពន្ធនាគារតាមបណ្តាខេត្តនានា[២] និង ២.៩៨២ នាក់ ឃុំឃាំងនៅក្នុងពន្ធនាគារក្នុងរាជធានីភ្នំពេញ ។

មកដល់បច្ចុប្បន្ននេះ អង្គការលីកាដូបានប្រមូលទិន្នន័យពិរុទ្ធជន ដែលកំពុងជាប់បណ្តឹងឧទ្ធរណ៍ ពីពន្ធនាគារចំនួន ៧ កន្លែង ដែលនៅក្រៅរាជធានីភ្នំពេញ ដោយរួមមានមណ្ឌលអប់រំកែប្រែទី៣ (ត្រពាំងផ្លុង ជិតព្រំប្រទល់ខ្មែរ-វៀតណាម) ផងដែរ។ យោងតាមទិន្នន័យដែលប្រមូលបាននោះ គេសង្កេតឃើញថា ប្រមាណ ៥៨% នៃទណ្ឌិតទាំង ៥.២៥៣ នាក់នោះ កំពុងជាប់ឃុំឃាំងនៅក្នុងពន្ធនាគារក្រៅរាជធានីភ្នំពេញ។ ទិន្នន័យទាំងនេះត្រូវ

[១] មាត្រា ១៤ (៥) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា។

[២] សម្រាប់របាយការណ៍នេះ ពាក្យថា "ពន្ធនាគារខេត្ត" គឺសំដៅទៅលើពន្ធនាគារទាំងឡាយណា ដែលស្ថិតនៅក្រៅរាជធានីភ្នំពេញ ហើយក្នុងនោះក៏រាប់បញ្ចូលទាំងមណ្ឌលអប់រំកែប្រែទី ៣ ផងដែរ។ ហើយពាក្យថា ពន្ធនាគារខេត្តនេះ ក៏ពុំបានរាប់បញ្ចូលពន្ធនាគារក្រុងតាខ្មៅទេ ដោយសារតែស្ថិតនៅជាប់រាជធានីភ្នំពេញ។

បានរាយការណ៍ដោយប្រធានពន្ធនាគារ។ ទិន្នន័យសរុប ទាំងនេះ អាចធ្វើការរៀបរាប់លំអិតទៅតាមពន្ធនាគារនីមួយៗ ដូចខាងក្រោម ៖ [៣]

| ពន្ធនាគារ | ពិរុទ្ធជនជាប់បណ្ដឹងឧទ្ធរណ៍ | ចំនួនទណ្ឌិតសរុប | ភាគរយជាប់បណ្ដឹងឧទ្ធរណ៍ |
|---|---|---|---|
| មណ្ឌលអប់រំកែប្រែទី៣ | ៣៥៥ | ១.៤០០ | ២៥.៤% |
| សៀមរាប | ១១០ | ១.០៣១ | ១០.៧% |
| កំពង់ធំ | ៥ | ១២១ | ៤.១% |
| ព្រះសីហនុ | ២៣ | ១១៤ | ២០.២% |
| កោះកុង | ១១ | ១១៣ | ៩.៧% |
| កំពង់ឆ្នាំង | ២១ | ១៦៣ | ១២.៩% |
| ពោធិ៍សាត់ | ១៥ | ១០៩ | ១៣.៨% |
| **សរុប** | **៥៤០** | **៣.០៥១** | **១៧.៧%** |

ចំនួនពិរុទ្ធជន ១៧.៧% ក្នុងទិន្នន័យសរុប ដែលបានលើកឡើងខាងលើ គឺសុទ្ធតែកំពុងជាប់បណ្ដឹងឧទ្ធរណ៍នៅតុលាការសាលាឧទ្ធរណ៍នៅភ្នំពេញ។ បើប្រៀបធៀបជាមួយពន្ធនាគារតាខ្មៅ ខេត្តកណ្ដាល ដែលនៅជាប់រាជធានីភ្នំពេញ មានតែពិរុទ្ធជន ៩ នាក់ ប៉ុណ្ណោះដែលកំពុងជាប់បណ្ដឹងឧទ្ធរណ៍។ ចំនួននេះ បើគិតជាភាគរយ គឺត្រឹមតែ ១.៦% ក្នុងចំណោមអ្នកទោសសរុបចំនួន ៥៤៧ នាក់។ តាមព័ត៌មានដែលអង្គការលីកាដូទទួលបាន មានពិរុទ្ធជនជាច្រើននាក់ដែលកំពុងជាប់បណ្ដឹងឧទ្ធរណ៍។

[៣] ទិន្នន័យទាំងនេះគឺទទួលបានពីថ្ងៃទី១៨-២២ ខែមករា-លើកលែងតែ មឌ៣ (ខែតុលា ឆ្នាំ២០០៩) និងពន្ធនាគារពោធិ៍សាត់ (ខែកុម្ភៈ ឆ្នាំ២០០៩)។

តាមរបាយការណ៍បានឱ្យដឹងថា នៅមណ្ឌលអប់រំកែប្រែទី២ និងពន្ធនាគារប៉ៃស៊្ហ ពុំមានពិរុទ្ធជនណាជាប់បណ្តឹងឧទ្ធរណ៍ទេ បច្ចុប្បន្ននេះ។ ចំណែកនៅមណ្ឌលអប់រំកែប្រែទី១ វិញ ដែលជាពន្ធនាគារធំជាងគេបង្អស់នៅរាជធានីភ្នំពេញ មន្ត្រីអះអាងថា ពុំបានដឹងចំនួនច្បាស់លាស់អំពីអ្នកជាប់បណ្តឹងឧទ្ធរណ៍នេះទេ[៤]។

ដូច្នេះ ក្នុងចំណោមអ្នកទោស ១.២៥៩ នាក់ នៅមណ្ឌលអប់រំកែប្រែទី២ ប៉ៃស៊្ហ និងតាខ្មៅ មានអ្នកជាប់បណ្តឹងឧទ្ធរណ៍តិចជាង ១ % ទៅទៀត។ គេបានដឹងច្បាស់ថា អ្នកជាប់បណ្តឹងឧទ្ធរណ៍មិនត្រូវបានដាក់ដាច់ដោយឡែកឡើយ។

## II. ទិដ្ឋភាពច្បាប់ជាតិ និងច្បាប់អន្តរជាតិ

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ថា "ត្រូវបញ្ជូនដោយគ្មានការពន្យាពេលឡើយ តាមបញ្ជារបស់ព្រះរាជអាជ្ញា ចំពោះពិរុទ្ធជនណាដែលជាប់បណ្តឹងឧទ្ធរណ៍ទៅពន្ធនាគារ ឬ មន្ទីរឃុំឃាំងណា ដែលនៅជិតសាលាឧទ្ធរណ៍ជាងគេបំផុត"[៥]។ នេះមានន័យថា តាមច្បាប់ គេត្រូវបញ្ជូនពិរុទ្ធជនភ្លាមបន្ទាប់ពីមានការជូនដំណឹងទៅមហាអយ្យការ អំពីកាលបរិច្ឆេទនៃសវនាការសាលាឧទ្ធរណ៍[៦]។ ប៉ុន្តែជាក់ស្តែង គេមិនដែលធ្វើការបញ្ជូនដូចនេះឡើយ។

វត្តមានជនជាប់ចោទនៅពេលសវនាការ នៅតុលាការសាលាឧទ្ធរណ៍ គឺជាកត្តាមួយយ៉ាងសំខាន់ក្នុងការធានាឱ្យបាននូវយុត្តិធម៌នៅកម្ពុជា។ ក្រមនីតិវិធីព្រហ្មទណ្ឌ បានបើកផ្លូវយ៉ាងទូលាយក្នុងការសួរដេញដោលជនជាប់ចោទ ដែលទង្វើបែបនេះ គឺជាការពិនិត្យឡើងវិញនូវការពិតទាំងឡាយនៃដំណើរការនីតិវិធី និងសេចក្តីសំរេចរបស់តុលាការសាលាដំបូង[៧]។

ចំពោះបញ្ហានេះ ច្បាប់អន្តរជាតិ ចែងមិនសូវជាក់លាក់ទេ ប៉ុន្តែក៏មិនរឹតត្បិតចំពោះសិទ្ធិជាមូលដ្ឋានក្នុងការប្តឹងឧទ្ធរណ៍ដែរ។ កត្តិការសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលកម្ពុជាផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩២

---

[៤] នៅមណ្ឌលអប់រំកែប្រែទី១ ពុំបានឱ្យដឹងច្បាស់អំពីតួលេខអ្នកជាប់បណ្តឹងឧទ្ធរណ៍ និងពិរុទ្ធជនដែលចង់បន្តទៅឧទ្ធរណ៍។ ជាទូទៅមន្ត្រីពន្ធនាគារ មិនមានព័ត៌មានច្បាស់លាស់អំពីពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍ទេ។ មន្ត្រីទាំងនោះ គ្រាន់តែលើកជាឧទាហរណ៍ឱ្យដឹងចំពោះពិរុទ្ធជនណាដែលបានប្តឹងទៅតុលាការសាលាឧទ្ធរណ៍តាមរយៈពួកគេតែប៉ុណ្ណោះ ដែលបណ្តឹងទាំងនេះមិនមែនធ្វើឡើងដោយមេធាវីរបស់ពិរុទ្ធជន ឬដោយព្រះរាជអាជ្ញានៃតុលាការសាលាដំបូងឡើយ។ ហេតុ ដូចនេះ តួលេខបណ្តឹងឧទ្ធរណ៍ទំនងជាមិនមានស្ថិតិច្បាស់លាស់ឡើយ។

[៥] មាត្រា ៣៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា។

[៦] មាត្រា ៣៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា។

[៧] មាត្រា ៣៩៣-៤០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្ពុជា។

បានចែងថា "ជនណាដែលត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋ ត្រូវទទួលបាននូវសិទ្ធិក្នុងការឱ្យតុលាការថ្នាក់លើពិនិត្យសារឡើងវិញនូវការផ្តន្ទាទោស ស្របតាមច្បាប់កំណត់"។ ច្បាប់នេះ ក៏តម្រូវឱ្យមានវត្តមានជនជាប់ចោទនៅក្នុងពេលសវនាការផងដែរ "ក្នុងការសម្រេចវិនិច្ឆ័យទោសបទឧក្រិដ្ឋណាមួយ"[៨]។ ដូច្នេះ ប្រសិនបើបណ្តឹងឧទ្ធរណ៍ណាមួយនៅកម្ពុជា ត្រូវបើកសវនាការពេញអង្គនោះ តាមខ្លឹមសារនៃអនុសញ្ញានេះ គឺតម្រូវឱ្យមានវត្តមានជនជាប់ចោទជានិច្ច នៅក្នុងសវនាការសាលាឧទ្ធរណ៍ ។

## III. ការដឹកជញ្ជូនអ្នកទោសនៅកម្ពុជា

ច្បាប់កម្ពុជា បានចែងថា ត្រូវដឹកជញ្ជូនពិរុទ្ធជន "ដោយមិនត្រូវពន្យាពេលឡើយ" ទៅដាក់ក្នុងពន្ធនាគារ ឬមន្ទីរឃុំឃាំងណាដែលនៅជិតសាលាឧទ្ធរណ៍បំផុត"។ តែផ្ទុយទៅវិញ ចំពោះបញ្ហាការដឹកជញ្ជូនបែបនេះមិនត្រូវបានអនុវត្តឡើងចំពោះពិរុទ្ធជននៅក្នុងពន្ធនាគារតាមបណ្តាខេត្តនានាឡើយ ។

មូលហេតុដែលបណ្តាលឱ្យមានបញ្ហានេះកើតឡើងមានលក្ខណៈសាមញ្ញជាទីបំផុតគឺៈ អគ្គនាយកដ្ឋានពន្ធនាគារស្ទើរតែគ្មានមធ្យោបាយសម្រាប់ដឹកជញ្ជូនអ្នកទោសផ្លូវឆ្ងាយទាល់តែសោះ[៩]។ មធ្យោបាយដឹកជញ្ជូនគឺស្ទើរតែគ្មានតែម្តង។ ទោះបីជាពេលខ្លះ អគ្គនាយកដ្ឋានជួយដឹកជញ្ជូនអ្នកទោសយ៉ាងច្រើនពីកន្លែងមួយទៅកន្លែងមួយទៀតដើម្បីកាត់បន្ថយភាពចង្អៀតលើសចំនួនក៏ដោយ ប៉ុន្តែការដឹកជញ្ជូនពិរុទ្ធជនទៅសាលាឧទ្ធរណ៍ គឺជាការទទួលខុសត្រូវរបស់ពន្ធនាគារនីមួយៗ។ ដូច្នេះ បើពិនិត្យទៅឃើញថា លទ្ធភាពក្នុងការដឹកជញ្ជូនអ្នកទោសរបស់ពន្ធនាគារតាមបណ្តាខេត្តទាំងនោះ គឺនៅមានកម្រិតទាបនៅឡើយ។ ជាក់ស្តែង តាមការសម្ភាសន៍របស់លីកាដូ ជាមួយនាយកពន្ធនាគារមួយចំនួនបានឱ្យដឹងថា ពួកគាត់ "គ្មានមធ្យោបាយ" សម្រាប់ដឹកជញ្ជូនពិរុទ្ធជនទៅសាលាឧទ្ធរណ៍ទេ"។ តាមការសាកសួរបានឱ្យដឹងថា ពន្ធនាគារខេត្តពោធិ៍សាត់ ធ្លាប់បានដឹកជញ្ជូនពិរុទ្ធជន ទៅសាលាឧទ្ធរណ៍ ៣ ដងដែរ ចាប់តាំងពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ននេះ ។

---

[៨] មាត្រា ១៤ (៣) (ឃ) នៃកតិកាសញ្ញាអន្តរជាតិ។

[៩] មធ្យោបាយដឹកជញ្ជូន ហាក់ដូចជាមិនសូវមានបញ្ហាប៉ុន្មានទេ។ ឧទាហរណ៍ អគ្គនាយកដ្ឋានបានរាយការណ៍កាលពីខែកញ្ញា ឆ្នាំ២០០៩ កន្លងទៅថា ក្នុងរយៈពេល ៨ ខែ ដើមឆ្នាំ២០០៩ មានអ្នកទោសចំនួន ១.៣១៦ នាក់ត្រូវបានដឹកជញ្ជូនទៅមក ដើម្បីចូលរួមសវនាការនៅសាលាដំបូងរាជធានីភ្នំពេញ។ នេះគឺជាអ្នកទោសក្នុងចំណោម ៣៨០០ នាក់ ដែលមានក្នុងខែកញ្ញា ឆ្នាំ២០០៩ (សូមមើលរបាយការណ៍ស្តីពីការរីកចម្រើន របស់អគ្គនាយកដ្ឋានពន្ធនាគារ និងការលំបាកក្នុងការគ្រប់គ្រងពន្ធនាគារ ក្នុងរយៈពេល៦ ខែដំបូងនៃឆ្នាំ២០០៩" ទំព័រ ៦ ខែកញ្ញា ឆ្នាំ២០០៩ ។

កាលពីខែកញ្ញា កន្លងទៅ អគ្គនាយកដ្ឋានពន្ធនាគារ បានចេញនូវសេចក្តីថ្លែងការណ៍មួយ ដោយបានទទួលស្គាល់ថា "សាលាឧទ្ធរណ៍មានតែមួយគត់នៅរាជធានីភ្នំពេញ ហើយការដឹកជញ្ជូនពិរុទ្ធជនជួបការលំបាក អាស្រ័យដោយខ្វះមធ្យោបាយនិងធនធាន ហើយអគ្គនាយកដ្ឋានកំពុងគិតគូរជាមួយតុលាការដើម្បីដោះស្រាយបញ្ហានេះ"[១០] ។

ក្នុងករណីជាច្រើន កង្វះមធ្យោបាយពុំមែនជាបញ្ហាចោទខ្លាំងទេ។ ពន្ធនាគារជាច្រើនសុទ្ធតែមានរថយន្តដែលអាចដឹកជញ្ជូនអ្នកទោសបាន ហើយរថយន្តទាំងនោះ ភាគច្រើនជាអំណោយរបស់អង្គការមិនមែនរដ្ឋាភិបាល ឬអំណោយរបស់រដ្ឋាភិបាលបរទេសនានា។ ប៉ុន្តែ បញ្ហាចម្បងគឺ កង្វះប្រេងឥន្ធនៈ។ នាយកពន្ធនាគារម្នាក់បានប្រាប់លីកាដូឱ្យបានដឹងថា រដ្ឋផ្តល់ប្រេងត្រឹមតែ ៨០០ លីត្រប៉ុណ្ណោះក្នុង ១ ខែ ដែលអាចត្រឹមតែប្រើម៉ាស៊ីនភ្លើងពេលយប់ រយៈពេល ៣ ម៉ោង ក្នុងមួយថ្ងៃ [១១] ។ នេះវាក្លាយទៅជាបញ្ហាធម្មតាទៅហើយសម្រាប់ពន្ធនាគារនៅកម្ពុជា ដោយពន្ធនាគារភាគច្រើនពុំមានបណ្តាញអគ្គិសនីទៅដល់ ជាពិសេស ពន្ធនាគារដែលទើបកសាងថ្មីៗ នៅតាមខេត្តមួយចំនួន។ ដូច្នេះ របបប្រេងដែលរដ្ឋផ្តល់ឱ្យទាំងប៉ុន្មាន គឺត្រូវប្រើប្រាស់សម្រាប់ម៉ាស៊ីនភ្លើងស្ទើរតែទាំងអស់។ ដូចជានៅពន្ធនាគារខេត្តពោធិ៍សាត់ ប្រធានពន្ធនាគារបានអះអាងថា ប្រេងសាំងសម្រាប់ចាក់រថយន្តទៅភ្នំពេញ គឺសាលាខេត្តជាអ្នកជួយផ្តល់ថវិកា[១២] ។

កង្វះបុគ្គលិកក៏ជាបញ្ហាធំមួយដែរ។ ចំពោះខេត្តឆ្ងាយ ការធ្វើដំណើរទៅមកភ្នំពេញអាចត្រូវប្រើប្រាស់បុគ្គលិកមួយចំនួនសម្រាប់រយៈពេល ២-៣ ថ្ងៃ ឬ លើសពីនេះ។ នាយកពន្ធនាគារភាគច្រើនបានអះអាងថា ពួកគាត់ពុំមានបុគ្គលិកច្រើនគ្រប់គ្រាន់ដើម្បីបម្រើការដឹកជញ្ជូននេះទេ។ ហើយទោះបីជាមានបុគ្គលិកក៏ដោយ ក៏ពុំមានថវិកាសម្រាប់ចំណាយលើបេសកកម្មនេះដែរ ជាពិសេស ការដឹកជញ្ជូន និងការពារពិរុទ្ធជនទៅមក សាលាឧទ្ធរណ៍នេះតែម្តង ហើយបញ្ហានេះ កើតឡើងជាប្រចាំ និងញឹកញាប់ទៀតផង។

ចុងបញ្ចប់ ទោះបីជាអាចធ្វើដំណើរទៅភ្នំពេញបានដោយងាយក៏ដោយ ការឃុំឃាំងពិរុទ្ធជនដែលជាប់បណ្តឹងឧទ្ធរណ៍នៅតែមានតាមបណ្តាខេត្តដដែល។ ក្រៅពីការចំណាយច្រើន ការមិនបញ្ជូនមកពន្ធនាគារ ដែលនៅជិតតុលាការសាលាឧទ្ធរណ៍ ឬការខកខានមិនបានចូលរួមនៅក្នុងសវនាការតុលាការសាលាឧទ្ធរណ៍ វាគឺជាកត្តាដែល

---

[១០] របាយការណ៍ដដែល។

[១១] ត្រូវមានរបបប្រេង សម្រាប់ការដឹកជញ្ជូនផ្សេងៗទៀតផង ដូចជា ទៅមន្ទីរ និងទៅតុលាការខេត្តជាដើម។ អ្នកទោសភាគច្រើនដែលលីកាដូ បានសម្ភាសន៍ និយាយថា ពួកគេចេញថវិកាចំណាយដោយខ្លួនឯងពេលត្រូវឡើងតុលាការ ឬ ទៅពេទ្យម្តងៗ។

[១២] ពន្ធនាគារប្រើរថយន្តរបស់អង្គភាព ដើម្បីដឹកជញ្ជូនពិរុទ្ធជនយកទៅផ្ញើនៅ ពន្ធនាគារតាខ្មៅ ហើយពន្ធនាគារតាខ្មៅជួយផ្តល់ រថយន្ត និង ប្រេងឥន្ធនៈ ទៅមកសាលាឧទ្ធរណ៍។

ធ្វើឱ្យពិរុទ្ធជនទាំងនោះបាត់បង់ប្រយោជន៍លើផ្នែកច្បាប់ គឺសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ខ្លួន។ មេធាវី ដែលការពារបណ្តឹងឧទ្ធរណ៍ភាគច្រើន សុទ្ធតែរស់នៅរាជធានីភ្នំពេញ ហើយរួមផ្សំជាមួយនឹងការទទួលកាន់ករណីយ៉ាងច្រើនលើសលប់ ព្រមទាំងការធ្វើដំណើរផ្លូវឆ្ងាយផងនោះ ហេតុដូចនេះ ធ្វើឱ្យមេធាវីទាំងនោះស្ទើរតែគ្មានពេលទៅជួបកូនក្តី ដែលជាប់បណ្តឹងឧទ្ធរណ៍នៅតាមខេត្តទាំងនោះទៅហើយ។

តាមការពិត ទោះបីជាពន្ធនាគារខេត្តពោធិ៍សាត់បានដឹកជញ្ជូនពិរុទ្ធជនទៅសាលាឧទ្ធរណ៍ក៏ដោយ មើលទៅមធ្យោបាយដឹកជញ្ជូន ហាក់ដូចជាពុំមែនជាបញ្ហាចោទខ្លាំងទេ។ នាយកពន្ធនាគារ បានប្រាប់យើងថា កាលពីដើម គេដឹកជញ្ជូនពិរុទ្ធជនទៅសាលាឧទ្ធរណ៍នៅថ្ងៃបើកសវនាការតែម្តង ឬ ទៅមួយថ្ងៃមុន ហើយពេលខ្លះ យកពិរុទ្ធជនទាំងនោះទៅផ្ញើនៅពន្ធនាគារតាខ្មៅ។ ធ្វើដូច្នេះ ពិរុទ្ធជនទាំងនោះ ពុំអាចមានពេលជួបមេធាវីរបស់ខ្លួនបានឡើយ។

## IV. ធាតុពិតៈ សវនាការតុលាការសាលាឧទ្ធរណ៍ដោយគ្មានជនជាប់ចោទ

តើកង្វះមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធនាគារ បានបណ្តាលឱ្យមានផលប៉ះពាល់អ្វីខ្លះដល់ពិរុទ្ធជនដែលជាប់បណ្តឹងឧទ្ធរណ៍? ដូចដែលប្រធានពន្ធនាគារម្នាក់បានប្រាប់យើងទាំងមិនសូវសប្បាយចិត្តថា ពិរុទ្ធជនអាចទៅចូលរួមសវនាការសាលាឧទ្ធរណ៍ "លុះត្រាតែមានថវិកាធ្វើដំណើរដោយខ្លួនឯង"។

ឱកាសនិយម របស់មន្ត្រីពន្ធនាគារដែលមានប្រាក់បៀវត្សតិចតួច នោះយើងមិនភ្ញាក់ផ្អើលទេ។ បញ្ហាកង្វះការដឹកជញ្ជូនពិរុទ្ធជនដូចលើកឡើងខាងលើជាឱកាសមួយដ៏ល្អសម្រាប់អំពើពុករលួយ ហើយបើតាមការសិក្សាស្រាវជ្រាវរបស់លីកាដូ បានបង្ហាញឱ្យឃើញថា ការទារថវិកាពីអ្នកទោស ដើម្បីដឹកជញ្ជូនទៅតុលាការនោះ គឺជាការអនុវត្តយ៉ាងទូលំទូលាយទៅហើយ សូម្បីតែពិរុទ្ធជននៅពន្ធនាគារភ្នំពេញក៏ត្រូវគេទារឱ្យជួយចេញថ្លៃដឹកជញ្ជូនដែរ[១៣]។ ការធានាឱ្យមានការដឹកជញ្ជូន គឺជាការចំណាយច្រើនណាស់ ដោយសារតែផ្លូវឆ្ងាយ និងការចំណាយផ្សេងៗទៀត។

ទីបំផុត គេនៅមានការសង្ស័យថា តើពិរុទ្ធជននៅតាមបណ្តាខេត្តនានា អាចមានលទ្ធភាពចំណាយលើការដឹកជញ្ជូនទៅភ្នំពេញដែរឬទេ ខណៈដែលសវនាការសាលាឧទ្ធរណ៍របស់ពួកគេចេះតែដំណើរការទៅដោយកំបាំងមុខ ហើយឱកាសបណ្តឹងឧទ្ធរណ៍ប្រកបដោយយុត្តិធម៌ របស់ពួកគេត្រូវកន្លងផុត។ ហើយការខកខានមិនបានចូលរួមនា

[១៣] សូមមើល ឧ. របាយការណ៍លីកាដូៈ ស្ថានភាពពន្ធនាគារនៅកម្ពុជា ២០០២ និង ២០០៣ ទំ. ២០។ ក្នុងពេលសរសេររបាយការណ៍នោះ តម្លៃដឹកជញ្ជូន ពី ម១ និង ម២ ទៅមកតុលាការរាជធានីភ្នំពេញ និងបន្ទាយមានជ័យ មានចាប់ពី ៥ ទៅ ២០ ដុល្លាអាមេរិក។ តាមរបាយការណ៍ក៏បានឱ្យដឹងថា មានអ្នកទារថវិកាពីអ្នកទោស និងគ្រួសារដើម្បីធានាឱ្យតុលាការកំណត់នូវកាលបរិច្ឆេទសវនាការ និង ប្រមូលឯកសារច្បាប់ពាក់ព័ន្ធគ្រប់គ្រាន់។

ពេលសវនាការនៅតុលាការសាលាឧទ្ធរណ៍ អាចធ្វើឱ្យបណ្តឹងឧទ្ធរណ៍គ្មានន័យ ដោយស្ថានភាពជុំវិញពិរុទ្ធជនទាំងនេះខុសពីការពិត ។ ពួកគេគ្មានជម្រើស ហើយត្រូវបានរារាំងដោយឧបសគ្គទាំងនេះ ។

កង្វះលទ្ធភាពរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្នុងការផ្តល់មធ្យោបាយដឹកជញ្ជូនពិរុទ្ធជនចូលរួមក្នុងសវនាការសាលាឧទ្ធរណ៍ វាបានធ្វើឱ្យបាត់បង់នូវដំណើរការវិនិច្ឆ័យទោសប្រកបដោយយុត្តិធម៌ ។ អង្គការលីកាដូ ជឿជាក់ថា គេត្រូវចាត់វិធានការជាបន្ទាន់ដើម្បីដោះស្រាយបញ្ហាចាំបាច់ចំពោះមុខទាំងនេះ ។

## V. អនុសាសន៍

**១. វិធីសាស្ត្រត្រូវធ្វើបន្ទាន់:** អគ្គនាយកដ្ឋាន មិនគួរផ្ទេរពិរុទ្ធជនណាដែលជាប់បណ្តឹងឧទ្ធរណ៍ទៅខេត្តឡើយ មានន័យថាអ្នកទាំងនោះត្រូវរងចាំរហូតដល់ចប់យុត្តាធិការរបស់ឧទ្ធរណ៍សិន។

ជំហានដំបូង ហើយចាំបាច់បំផុតគឺ អគ្គនាយកដ្ឋាន ត្រូវពិនិត្យមើលស្ថានភាពច្បាប់របស់ពិរុទ្ធជនទាំងឡាយឱ្យបានហ្មត់ចត់ជាងមុន មុននឹងបញ្ជូនពួកគេទៅពន្ធនាគារណាមួយនៅក្រៅរាជធានីភ្នំពេញ។ មិនត្រូវផ្ទេរអ្នកទោសនៅភ្នំពេញឱ្យទៅខេត្តណាមួយមុនពេលចប់ឧទ្ធរណ៍ឡើយ។ នេះមានន័យថា ត្រូវរងចាំរហូតដល់ចប់យុត្តាធិការរបស់ឧទ្ធរណ៍សិន ក្នុងករណីដែលអ្នកទោសណាកំពុងប្តឹងឧទ្ធរណ៍។

វិធីសាស្ត្រនេះ ក៏មិនអាចដោះស្រាយបញ្ហាទាំងមូលបានដែរ ដោយគ្រប់អ្នកទោសទាំងអស់ពុំមែនសុទ្ធតែត្រូវផ្តន្ទាទោសនៅភ្នំពេញទេ។ ប៉ុន្តែការធ្វើបែបនេះ អាចដោះស្រាយបញ្ហាចំពោះមុខបានភ្លាមៗ ហើយងាយស្រួលទៀតផង។ ប្រសិនបើពិរុទ្ធជនណាកំពុងជាប់បណ្តឹងឧទ្ធរណ៍ ហើយកំពុងជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ នោះវាមិនបញ្ហាទេសម្រាប់ពួកគាត់ ដែលត្រូវឃុំនៅទីនោះរហូតដល់ចប់បណ្តឹងឧទ្ធរណ៍។

វិធីសាស្ត្រនេះ មើលទៅហាក់ដូចជាពិបាកបន្តិច ប៉ុន្តែការដឹកជញ្ជូនអ្នកទោសចំនួន១០០នាក់ កាលពីខែកញ្ញា ឆ្នាំ២០០៩ កន្លងទៅ ពីមណ្ឌលអប់រំកែប្រែទី១ ទៅមណ្ឌលអប់រំកែប្រែទី៣ យ៉ាងហោចណាស់មានពិរុទ្ធជនចំនួន៣នាក់ ដែលរឿងក្តីរបស់ពួកគេកំពុងស្ថិតនៅកណ្តាលទី នៃដំណើការនីតិវិធីរបស់តុលាការសាលាឧទ្ធរណ៍។ លីកាដូ ក៏បានជួយអន្តរាគមន៍លើសិទ្ធិបើកសវនាការចំពោះមុខ នៅតុលាការសាលាឧទ្ធរណ៍ដល់ពិរុទ្ធជនទាំងបីនាក់នោះ។ ក្រោយពីការខិតខំប្រឹងប្រែងចរចារអស់រយៈពេល៣ខែ ជាមួយអាជ្ញាធរពាក់ព័ន្ធ នៅទីបំផុតពិរុទ្ធជនទាំងបីនាក់នោះត្រូវបានដឹកត្រឡប់មកឃុំនៅមណ្ឌលអប់រំកែប្រែទី១វិញ ដើម្បីរងចាំចូលខ្លួននៅថ្ងៃបើកសវនាការនៅតុលាការសាលាឧទ្ធរណ៍ [១៤]។

អ្វីដែលអាចជាឧបសគ្គក្នុងការដោះស្រាយបញ្ហានេះ គឺការធានាឱ្យមាននូវទំនាក់ទំនងជាប្រចាំ រវាងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ជាពិសេសការិយាល័យរបស់អយ្យការ។ នៅក្នុងការសម្ភាសន៍របស់យើង មន្ត្រីពន្ធនាគារមួយចំនួនបានលើកឡើងថា ជួនកាលអ្នកទោសត្រូវបានដឹកជញ្ជូនទៅដោយសារតែក្រសួងយុត្តិធម៌ មិនបានរាយការណ៍ប្រាប់ក្រសួងមហាផ្ទៃភ្លាមៗអំពីការជាប់បណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ។

---

[១៤] ជាផ្នែកមួយនៃការដឹកជញ្ជូនពិរុទ្ធជនទាំង៣នាក់នោះ។ ម១ បានបញ្ជូនអ្នកទោស ៥០ នាក់ ទៅម៣ ដើម្បីកាត់បន្ថយ "ភាពចង្អៀត"។ លីកាដូ ក៏ពុំទាន់បានដឹងច្បាស់ដែរថា ក្នុងចំណោម ៥០ នាក់នោះ ប៉ុន្មាននាក់ជាប់បណ្តឹងឧទ្ធរណ៍ទេ។

ឧបសគ្គមួយផ្សេងទៀតនោះគឺថា នៅពន្ធនាគារភ្នំពេញតែងតែមានភាពចង្អៀតណែនខ្លាំង តួយ៉ាងដូចជា មណ្ឌលអប់រំកែប្រែទី១ ឡើងដល់ ១៧៣% ដែលត្រូវបានឃុំលើសពីសមត្ថភាពផ្ទុករបស់ពន្ធនាគារ មណ្ឌលអប់រំកែប្រែទី២ចំនួន ២៥១% និងនៅពន្ធនាគារតាខ្មៅឡើងរហូតដល់ ៣០៩% លើកលែងតែពន្ធនាគារប៉េហ្ស៊ី ប៉ុណ្ណោះដែលមានចំនួនអ្នកទោសត្រឹមតែ៨៤%។ ដោយភាពចង្អៀតណែនខ្លាំងនេះ ត្រូវបានកើតចេញពីបញ្ហាចម្រុះជាច្រើន វាជាការផ្តល់សញ្ញាអោយដំណឹងជាមុនថា ចំនួនអ្នកទោសតិចជាង១% ក្នុងចំណោមពន្ធនាគារទាំង៣ ដែលកំពុងជាប់បណ្តឹងឧទ្ធរណ៍ ក៏ជាចំណែកមួយក្នុងបញ្ហានេះផងដែរ។ នេះជាការបង្ហាញយ៉ាងជាក់ច្បាស់ថា គឺជាការខកខានលើការបម្រុងទំហំអាគារ ជាអាទិភាពសំរាប់អ្នកជាប់បណ្តឹងឧទ្ធរណ៍ឡើយ។ លីកាដូ សូមផ្តល់ជាអនុសាសន៍លើបញ្ហានេះថា ពន្ធនាគារដូចបានរៀបរាប់ខាងលើ ត្រូវតែចាប់ផ្តើមពីឥឡូវនេះ នៅក្នុងការរៀបចំជា អាទិភាពនូវទំហំអាគារបម្រុងមួយសមស្រប ដើម្បីដោះស្រាយលើករណីពិរុទ្ធជនដែលកំពុងជាប់បណ្តឹងឧទ្ធរណ៍។

វិធីសាស្ត្រមួយដែលអាចជាវិធីសាស្ត្រយូរអង្វែង គឺតម្រូវឱ្យមានការសម្រួលបន្ទប់ឃុំឃាំង ដែលតម្រូវឱ្យមានការពិនិត្យឱ្យបានហ្មត់ចត់អំពីបញ្ហានៃភាពចង្អៀត និងកត្តាទាំងឡាយដែលបណ្តាលឱ្យចង្អៀតនេះ។ បញ្ហានេះវាហួសពីវិសាលភាពនៃរបាយការណ៍នេះ ប៉ុន្តែជាចំណុចគួឱ្យកត់សំគាល់ ដែលថារហូតមកដល់ខែធ្នូ ឆ្នាំ២០០៩ កន្លងទៅនេះអ្នកទោសចំនួន៣៣.២% គឺជាពិរុទ្ធជន។ ពិរុទ្ធជនចំនួន៥០០នាក់ ដែលត្រូវបានឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់។ នៅខែមករា ឆ្នាំ២០០៨ ចំនួនពិរុទ្ធជនមាន តែ ២៦.៤ % ប៉ុណ្ណោះនៃចំនួនអ្នកទោសសរុប [១៥]។

លើសពីនេះទៅទៀត ចំនួនអ្នកទោសនៅក្នុងពន្ធនាគារ ដែលលីកាដូ បានឃ្លាំមើល មានការកើនឡើងទ្វេរដងបើធៀបជាមួយនឹងចំនួនអ្នកទោស កាលពី៥ឆ្នាំកន្លងទៅ គឺពី ៥.៩៦៨ ទៅ ១២.២៣១ នាក់ គិតត្រឹមខែធ្នូ ឆ្នាំ២០០៩ កន្លងទៅនេះ។ ប្រសិនបើធៀបទៅនឹងចំនួនអ្នកទោសកាលពី១០ឆ្នាំមុន ដែលមានត្រឹមតែ៣.៥០១នាក់ ដែលចំនួននេះស្ទើរតែកើនឡើងដល់ទៅបួនដងឯណោះ។ អត្រាកំណើនអ្នកទោសក្នុងមួយឆ្នាំ២០០៩ គឺ១៥%។ មានករណីកាន់តែច្រើនឡើងៗ ដែលតុលាការខកខាន ជ្រើសរើសយកជម្រើស ដូចជា ការឱ្យជនត្រូវចោទនៅក្រៅឃុំ ការព្យួរទោស ការដោះលែងបណ្តោះអាសន្នដោយមានល័ក្ខខ័ណ្ឌ និងការបើកសវនាការឱ្យបានឆាប់ប្រសើជាង ដោយគ្រាន់តែយកជំរើសតែមួយគត់ គឺធ្វើការឃុំខ្លួនជនត្រូវចោទនៅឯពន្ធនាគារ ជម្រើសទាំងឡាយខាងលើនេះ គឺជាការបង្ហាញយ៉ាងច្បាស់នូវការជួយសន្សំថវិការបស់អគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ដែលកំពុងតែស្ពួចស្តើងស្រាប់ទៅហើយនោះ ។

[១៥] ទិន្នន័យទាំងអស់ដកស្រង់ចេញពីពន្ធនាគារ ១៨ ដែល លីកាដូ តែងតែឃ្លាំមើល។

**២. វិធីសាស្ត្រប្រើពេលយូរអង្វែង:** បង្កើនលទ្ធភាពការដឹកជញ្ជូនអ្នកទោសរបស់អគ្គនាយកដ្ឋាន និង ប្រមូលផ្ដុំការទទួលខុសត្រូវក្នុងការដឹកជញ្ជូនទៅមកសាលាឧទ្ធរណ៍។

ដំណោះស្រាយដ៏សមរម្យបំផុត គឺតម្រូវឱ្យអគ្គនាយកដ្ឋាន ឧបត្ថម្ភថែមទៀតដល់ពន្ធនាគារ ដូចជា បុគ្គលិក និងថវិកាសម្រាប់ដឹកជញ្ជូន ដើម្បីពន្ធនាគារខេត្តទាំងឡាយមានលទ្ធភាពអាចដឹកជញ្ជូន ពិរុទ្ធជនទៅចូលរួមសវនាការសាលាឧទ្ធរណ៍នៅភ្នំពេញបានជាប្រចាំ ដោយកំណត់យកភ្នំពេញ ជាចំណុចកណ្ដាលតែមួយគត់សម្រាប់អ្នកទោសដែលជាប់បណ្ដឹងឧទ្ធរណ៍[១៦] ។ វាជាការប្រសើរ ប្រសិនបើមានការកំណត់ផែនហិរញ្ញវត្ថុជាមុនលើកាងារនេះ ដោយហេតុថា ការមកដល់នៃអ្នកទោសជាប់បណ្ដឹងឧទ្ធរណ៍ពីតាមបណ្ដាខេត្តមកពន្ធនាគារភ្នំពេញ តំរូវឱ្យមានស្ថេរភាពមួយ នៅខណៈដែលការបញ្ជូនអ្នកទោសពីតាមបណ្ដាខេត្ត-ក្រុងនេះអាចនឹងធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់ថវិការដ្ឋ។

ការឧបត្ថម្ភបន្ថែមត្រូវតែពិនិត្យលើតំរូវការផ្សេងៗដូចជា : ទំហំសំរាប់ការស្នាក់នៅ សំរាប់អ្នកទោសដែលត្រូវបានបញ្ជូនពីតាមបណ្ដាខេត្ត ហើយត្រូវឃុំនៅភ្នំពេញក្នុងកំឡុងពេលជាប់បណ្ដឹងឧទ្ធរណ៍។ ទំនាក់ទំនងរវាងនាយកពន្ធនាគារ និងថ្នាក់គ្រប់គ្រងពាក់ព័ន្ធ អំពីការធ្វើចំណាត់ថ្នាក់អ្នកទោស និងស្វែងយល់អំពីតម្រូវការពិសេស។ បង្កើតក្រុមការងារប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឱ្យមានទំនាក់ទំនងរវាងពន្ធនាគារភ្នំពេញ និងតុលាការសាលាឧទ្ធរណ៍ និងការដឹកជញ្ជូនទៅមកពីតុលាការនៅពេលដែលអ្នកទោសមកដល់ភ្នំពេញ[១៧] ។

មានប្រព័ន្ធមួយដែលបានរៀបចំយ៉ាងណាដើម្បីឱ្យប្រាកដថា ការឃុំអ្នកទោសនៅភ្នំពេញ មិនត្រូវលើសថេរៈវេលាកំណត់ដោយច្បាប់។ អ្នកទោសត្រូវការជួបមេធាវីរបស់ពួកគេជាមុន ដើម្បីរៀបចំករណីរបស់គេឱ្យបានត្រឹមត្រូវ។ មេធាវីមួយចំនួន ដែលមានទីតាំងការិយាល័យតែមួយគត់នៅរាជធានី ត្រូវតែឱ្យប្រាកដថា ពួកគេមានពេលវេលាគ្រប់គ្រាន់ដើម្បីជួបកូនក្ដីនៅឯខេត្ត។ ក្នុងករណីខ្លះ មេធាវីត្រូវការពេលវេលាពីរបីសប្ដាហ៍ក៏មាន។

ដំណោះស្រាយនេះ ប្រឈមនឹងឧបសគ្គយ៉ាងធ្ងន់ធ្ងរ ដូចជា ថវិកា ការហ្វឹកហ្វឺន និងការចំណាយពេលវេលាក្នុងការរៀបចំរចនាសម្ព័ន្ធជាដើម។ ដូចនេះ គួរតែចាត់ទុកជាគោលដៅយូរអង្វែង។

---

[១៦] ជាការពិតណាស់ដែលថា មានជម្រើសផ្សេងទៀត ដែលតំរូវឱ្យបង្កើតតុលាការសាលាឧទ្ធរណ៍ នៅតាមបណ្ដាខេត្ត-ក្រុង នេះគឺជាជំរើសដ៏ល្អមួយសំរាប់ដំណោះស្រាយ ដែលវាជាបន្ទុករបស់ក្រសួងយុត្តិធមិសុទ្ធសាធ វាមិនមែនជាកិច្ចការរបស់អគ្គនាយកដ្ឋានពន្ធនាគារឡើយ។ ទោះជាយ៉ាងណាក៏ដោយ វាជាជម្រើសដែលត្រូវកាពេលវេលា យូរអង្វែងដើម្បីបំពេញកិច្ចការនេះ ហេតុដូចនេះការដឹកជញ្ជូនពិរុទ្ធជនជាប់បណ្ដឹងឧទ្ធណ៍ពីតាមបណ្ដាខេត្ត មកតុលាការសាលាឧទ្ធរណ៍ វាជាតំរូវការចាំបាច់បំផុត ដែលត្រូវធ្វើនៅពេលនេះ។

[១៧] ការចំណាយក្នុងការដឹកជញ្ជូនអាចត្រូវបានកាត់បន្ថយ ប្រសិនបើសាលាឧទ្ធរណ៍អាចរៀបចំឡើងវិញនូវការងាររបស់ខ្លួន ហើយផ្ដោតការយកចិត្តទុកដាក់លើបណ្ដឹងឧទ្ធរណ៍នៅតាមពន្ធនាគារ តាមខែនីមួយៗ ។ នេះមិនមែនងាយស្រួលទេ អាស្រ័យដោយតុលាការ។

អនុសាសន៍ចុងក្រោយ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវបង្កើតឱ្យមានទំនាក់ទំនងគ្នាជាប្រចាំរវាងពន្ធនាគារ និងតុលាការ ។ ដោយហេតុថា បច្ចុប្បន្ននេះ ចំនួនតួលេខពិតប្រាកដរបស់ពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍មិនត្រូវបានគេដឹងឡើយ ។ ពន្ធនាគារគួរតែរក្សាទុកព័ត៌មានលំអិតអំពីដំណើរនីតិវិធីនៃរឿងក្តីរបស់ពិរុទ្ធជននិមួយៗ រួមទាំងករណីបណ្តឹងឧទ្ធរណ៍ ។ ឧទាហរណ៍ ការកំណត់អំពីស្ថានភាពនីតិវិធីរឿងក្តី គួរណាស់ត្រូវមានការបញ្ជាក់នៅក្នុងនីតិវិធីផ្សេងៗរបស់តុលាការក្នុងការទទួលយកពិរុទ្ធជនចំណូលថ្មី ។ តុលាការត្រូវអោយប្រាកដថាសាលក្រមសម្រេចដីកាផ្សេងៗរបស់តុលាការ និងឯកសារពាក់ព័ន្ធដ៏ទៃទៀតត្រូវតែបញ្ជូនមកពន្ធនាគារណាដែលជនជាប់ចោទកំពុងស្នាក់នៅ ។ នៅពេលមានការដឹកជញ្ជូនអ្នកទោសពីពន្ធនាគារមួយទៅពន្ធនាគារមួយ-អាជ្ញាធរពន្ធនាគារត្រូវតែប្រាកដថា អ្នកទាំងនោះមិនមានប៉ះពាល់លើសិទ្ធិ និងដំណើរការនីតិវិធីនៅតុលាការសាលាឧទ្ធរណ៍ឡើយ ។

http://www.licadho-cambodia.org